ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ២៩៩ អក-៩៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សូមជម្រាបមក

## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**កម្មវត្ថុ:** អំពីការអនុញ្ញាតអោយចោទប្រកាន់នគរបាលដែលបានប្រព្រឹត្តខុសច្បាប់ ។

ខ្ញុំសូមថ្លែងអំណរសរសើរយ៉ាងកក់ក្តៅ និងសូមគោរពអរគុណឯកឧត្តមយ៉ាងជ្រាលជ្រៅចំពោះការអនុញ្ញាតរបស់ក្រសួងមហាផ្ទៃបានចំនួនច្រើន តាំងពីខែធ្នូ ១៩៩៧ មក ឱ្យអយ្យការអមតុលាការខេត្ត-ក្រុង ចោទប្រកាន់នគរបាល ដែលបានប្រព្រឹត្តខុសច្បាប់នៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្ត-ក្រុង ការអនុញ្ញាតបានច្រើនហើយបានរហ័សនេះ ជាការរួមវិភាគទានដែលមានតម្លៃខ្ពស់ ក្នុងការការពារសិទ្ធិមនុស្សរបៀបរៀបរយសាធារណៈនិងសន្តិសុខក្នុងសង្គម ដើម្បីព្រះរាជាណាចក្រកម្ពុជាយើងឈានទៅជានីតិរដ្ឋបានឆាប់ ។

ខ្ញុំយល់ហើយសង្ឃឹមថា ការអនុញ្ញាតឱ្យចោទប្រកាន់បានច្រើន និងឆាប់រហ័សដូចនេះធ្វើអោយមន្ត្រីរាជការយើងនៅតែខេត្ត-ក្រុង ទាំងអស់ចាប់អារម្មណ៍លើការគោរពច្បាប់ និងគោរពសិទ្ធិមនុស្សមិនប្រព្រឹត្តអ្វីដែលធ្លាក់ខ្លួនទៅតុលាការផ្តន្ទាទោសឡើយ ។ នេះជាការរួមចំណែកធំធេងដែលរាជរដ្ឋាភិបាលចង់បានដើម្បីអោយសង្គមខ្មែរមានសណ្តាប់ធ្នាប់ និងសន្តិសុខតាមបំណងប្រាថ្នា របស់ប្រជាពលរដ្ឋក៏ដូចជារបស់សហគមអន្តរជាតិ ។

ខ្ញុំមានការត្រេកអរក្រៃលែង ហើយសូមគោរពសរសើរឯកឧត្តមទាំងពីរម្តងទៀត ដែលខ្ញុំជឿទុកចិត្តថា សហប្រតិបត្តិការជិតស្និតខ្លាំង និងម៉ឺងម៉ាត់របស់ក្រសួងយើងទាំងពីរ និងក្រសួងការពារជាតិ និងនាំមកនូវការគោរពច្បាប់បានទូទាំងប្រទេសក្នុងរយៈពេលមិនយូរខាងមុខនេះ ។

សូមឯកឧត្តមទទួលអំពីខ្ញុំនូវការគោរពរាប់អានខ្ពង់ខ្ពស់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន
- -ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ
- -ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- -រដ្ឋសភា (គណៈកម្មការការពារសិទ្ធិមនុស្ស)
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១
- -ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី២
- -ក្រសួងការពារជាតិ
- -អគ្គនាយកដ្ឋាននគរបាលជាតិ
- -តុលាការគ្រប់ជាន់ថ្នាក់
- -កាលប្បវត្តិ -ឯកសារ